# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ១៦២៨ បទ.

ថ្ងៃពុធ ១៥រោចខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកជូនភាគីពាក់ព័ន្ធនិងសាធារណជនចំនួន ៣០រូប ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) មានកិត្តិយសសូមជម្រាបជូនបណ្តាក្រុមហ៊ុន សហគ្រាសធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មីគ្រប់វិស័យ គ្រឹះស្ថានអប់រំស្រាវជ្រាវ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អ្នកវិជ្ជាជីវៈឌីជីថល សិស្សនិស្សិត(*"ភាគីពាក់ព័ន្ធ"*)ទាំងអស់ និងសាធារណជន មេត្តាជ្រាបថា **ក.ប.ទ.** នឹងរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត" នាថ្ងៃទី១-២ ខែកក្កដា ឆ្នាំ២០២៥។ បន្ថែមលើភាគីដែលបានទទួលការអញ្ជើញផ្ទាល់ **ក.ប.ទ.** សូមផ្តល់ឱកាសជូន ភាគីពាក់ព័ន្ធនិងសាធារណជន ចំនួន ៣០រូប ចូលរួមសិក្ខាសាលាខាងលើផងដែរ។ ដើម្បីស្នើសុំចូលរួម សូមបំពេញព័ត៌មានចាំបាច់និងភ្ជាប់ឯកសារសម្គាល់អត្តសញ្ញាណឱ្យបានត្រឹមត្រូវតាមរយៈឃ្យូអរកូដ ខាងក្រោមឱ្យបានមុនថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ១៧:០០នាទី ហើយក្រុមការងារ **ក.ប.ទ.** នឹងឆ្លើយតបវិញតាមករណីនីមួយៗ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈអ៊ីមែល ai-governance@mptc.gov.kh ឬទូរសព្ទលេខ ០៩៦ ៦៥១ ៣០០៣។

សេចក្តីដូចមានជម្រាបជូនខាងលើ សូមភាគីពាក់ព័ន្ធ និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ទម្រង់ស្នើសុំចូលរួម៖

https://go.gov.kh/mptc/3chn31

GO.gov.KH